01186611

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 01 / 2016
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
**E1/360**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ចន្ទ ទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥

## សវនាការលើអង្គសេចក្តី - ថ្ងៃ ៣៤១

រៀបចំដោយ៖ **ឯម ហ៊ុយ** និង Matthew McCarthy

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ , ចៅក្រម Jean-Marc LAVERGNE , ចៅក្រម យូរ ឧត្តរ |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ុយ, លោក Matthew McCarthy |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, កញ្ញា សុង ឆវ័ន្ត, លោក Dale Lysak |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, |

| |
|---|
| លោក ហុង គីមសួន, លោក វ៉ែន ពៅ, លោកស្រី ទី ស្រីនណា, លោក ឡោ ជុនធី |
| សាក្សី/ដើមបណ្ដឹង៖ (2-TCW-918) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, កញ្ញា សុក សុភ័គមណីកា, លោក ឈឿង សូភ័ក្ត, លោក មៀច សុវណ្ណា ,មេធាវីប្រឹក្សា លោក ម៉ម រិទ្ធា, លោក Richard LATTA |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.២២ | បញ្ចប់ម៉ោង៖ ១៦.០២ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.២៧ | បញ្ចប់ម៉ោង៖ ១០.៤២ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.២៨ | បញ្ចប់ម៉ោង៖ ១៤.៤៧ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ០៧ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.២១ | ០៩.២៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.២៤ | ០៩.២៥ |
| ចម្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការកោះហៅសាក្សីថ្មី ទាក់ទងទៅនឹងការប្រព្រឹត្តិជាក់លាក់លើជនជាតិវៀតណាម (E319/36 កឋាខណ្ឌ ១១,១២) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី នួនជា<br>មេធាវីការពារក្ដី ខៀវ សំផន<br>ចៅក្រម ក្លូឌា ហ្វេនស៍<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី ខៀវ សំផន | ៩.២៥<br>៩.២៧<br>៩.៣០<br>៩.៣២<br>៩.៣៧<br>៩.៤៣<br>៩.៤៥<br>៩.៥០ | ៩.២៧<br>៩.៣០<br>៩.៣១<br>៩.៣៧<br>៩.៤៣<br>៩.៤៥<br>៩.៤៩<br>៩.៥០ |

| | | | |
|---|---|---|---|
| ចម្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីទាក់ទិននឹងការប្រព្រឹត្តិជាក់លាក់លើជនជាតិចាម (E319/32) | អង្គជំនុំជម្រះ | ១៣.៣២ | ១៣.៣៥ |
| | សហព្រះរាជអាជ្ញា | ១៣.៣៥ | ១៣.៣៧ |
| | សហមេធាវីនាំមុខ | ១៣.៣៧ | ១៣.៣៨ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៣.៣៨ | ១៣.៥៥ |
| | មេធាវីការពារក្តី នួន ជា | ១៣.៥៥ | ១៣.៥៦ |
| | សហព្រះរាជអាជ្ញា | ១៣.៥៦ | ១៤.០៤ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៤.០៥ | ១៤.០៨ |
| ការតាំងសំណួរទៅសាក្សី (2-TCW-918) | សហព្រះរាជអាជ្ញា | ០៩.៥៤ | ១០.៥៩ |
| | សហមេធាវីនាំមុខ | ១០.៥៩ | ១១.១២ |
| | អង្គជំនុំជម្រះ | ១១.១៥ | ១៥.00 |
| | មេធាវីការពារក្តី នួន ជា | ១៥.០១ | ១៦.០២ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៣.៥៨ | ១៤.៤៤ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីត្រូវបានពន្យាដោយសារប្រព័ន្ធសោទស្សន៍មានបញ្ហា។

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ចម្លើយតបផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាក្នុងការកោះហៅសាក្សីថ្មី ទាក់ទិននឹងការប្រព្រឹត្តក្រុមគោលដៅជាក់លាក់លើជនជាតិវៀតណាម និងការទទួលយកឯកសារ ( E319/36 កឋាខណ្ឌ ១១,១២)**

សហព្រះរាជអាជ្ញាអន្តរជាតិស្នើថា អង្គជំនុំជម្រះគួរតែកោះហៅសាក្សីបន្ថែមសម្រាប់ការប្រព្រឹត្តលើក្រុមគោលដៅជាក់លាក់ជនជាតិវៀតណាមផ្អែកលើព័ត៌មានពីការដាក់បង្ហាញឯកសារដែល ក.ស.ច.ស បានសម្ភាសន៍ក្នុងសំណុំរឿង០០៣ និងស្នើសុំថា ការយល់ដឹងរបស់សាក្សីទៅនឹងការប្រព្រឹត្តលើក្រុមគោល

ដៅជាក់លាក់ជនជាតិវៀតណាមដែលបានស្នើ មិនទាន់មានការពិភាក្សាគ្រប់ជ្រុងជ្រោយនៅក្នុងចម្លើយរបស់គាត់ទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា។សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំថា សាក្សីដែលបានស្នើអាចផ្តល់ភ័ស្តុតាងទៅលើការប្រព្រឹត្តក្រុមគោលដៅជាក់លាក់ជនជាតិវៀតណាម។ សហព្រះ រាជអាជ្ញាអន្តរជាតិ ក៏បានស្នើសុំឱ្យទទួលយកភ័ស្តុតាងចំនួន ៣ ក្នុងចំណោម ៥ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលថ្មីៗនេះបានដាក់ឯកសារដោយ ក.ស.ច.ស។ សហមេធាវីគាំទ្រឱ្យមានការស្តាប់សាក្សីរូបនេះ ហើយគាំទ្រសំណើសុំឱ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ។ ក្រុមមេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងការកោះហៅសាក្សីដែលបានស្នើ ប៉ុន្តែខ្លួនបានស្នើសុំថា ប្រសិនបើ អ.ជ.ស.ដ យល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ចំនួន ៣ ដែលស្នើដោយសហព្រះរាជអាជ្ញា ដោយមិនទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន២ទៀត ដែលទើបតែបានដាក់បង្ហាញនោះទេ វានឹងលុបបំបាត់ភ័ស្តុតាងបរិបទសំខាន់ៗ។ មេធាវីការពារក្តី នួន ជា ស្នើសុំ អ.ជ.ស.ដ ទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន៥តែម្តង។ មេធាវីការពារក្តី ខៀវ សំផន ក៏ជំទាស់ទៅនឹងការកោះហៅសាក្សីដែលបានស្នើនោះដែរ។

**ចម្លើយតបផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទាក់ទិននឹងការប្រព្រឹត្តក្រុមគោលដៅជាក់លាក់លើជនជាតិចាម ( E319/32 )**

សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យទទួលយកភ័ស្តុតាងនូវកិច្ចសម្ភាសន៍ ចំនួន២៥ ដែលទាក់ទិនជាបឋមទៅនឹងការប្រព្រឹត្តក្រុមគោលដៅជាក់លាក់ជនជាតិចាម ដែលទើបតែអាចរកឃើញបាន បន្ទាប់ពីការចាប់ផ្តើមសវនាការ។ ខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនជំទាស់ទៅនឹងការស្នើសុំនោះទេ។ ទាំងមេធាវីការពារក្តី នួន ជា និងមេធាវី ខៀវ សំផន ជំទាស់ទៅនឹងការទទួលយកឯកសារទាំងអស់នេះ។ ក្នុងអំឡុងពេលនៃចម្លើយតបទាំងអស់នេះ មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យមានសេចក្តីសម្រេចមួយពី អ.ជ.ស.ដ លើសំណើមួយមិនទាន់បានសម្រេចឯកសារE370 ។ មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យមានសេចក្តីសម្រេចមួយទៅលើសំណើរបស់ខ្លួន ឯកសារ E364 ។ អ.ជ.ស.ដ យល់ឃើញថា អ.ជ.ស.ដ នឹងពិចារណាទៅនឹងចម្លើយតបផ្ទាល់មាត់ទាំងអស់នេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅលើសំណើក្នុងឯកសារ E319/32 ។

**សាក្សី (2-TCW-918)**

សហព្រះរាជអាជ្ញា សហមេធាវីនាំមុខ អង្គជំនុំជម្រះ មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅសាក្សី (2-TCW-918)។

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5657 | | 00061321-00061354; 00089771-00089790; 00347354-00061354 | DC-Cam Interview with IM Chem | P | 000613215 | 00089773 | 00347356 |
| E3/9094 | | 00734030-00734120; 00728641-00728705; 01123606-01123663 | DC-Cam: Khmer Rouge 'Trapeang Thma' Dam Construction Interview series: interview No.2 | P | 00734097-00734098; 00734104; 00734059-00734062; 00734089; 00734102; 00734090; 00734089; 00734112 | 00728689; 00728694; 00728672-00728673; 00728683; 00728686; 00728684; 00728683; 00728699 | 01123649-01123650; 01123653; 01123625-01123626; 01123644; 01123647; 01123645; 01123644; 01123658 |
| E3/9443 | | 00729869-00729919 | DC-Cam Promoting Accountability Project Field Trip's Report in Preah Netr Preah District, Banteay Meanchey Province June 14 to 19, 2011 | P | / | 00729874 | / |
| E3/9564 | E319/19.3.18 | 01003875-01003890; 01044791-01044810 | Written Record of Interview of MUN Mot, alias MUN Saroeun | C | 01003885 | 01044804 | / |
| E3/531 | D288/6.68.49 | 00333797-00333847 | Annex 49 – S-21 Prisoners Coming from the Northwest Zone | P | 00333797 | 00333797 | / |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9646 | | 01017015-01017071; 01139858-01139863 | Annex 2: Name list of prisoners entering on 28 June 1977 | P | 01017016 | 01139858 | / |
| E3/2254 | D108/26.273 | 00086763-00086768; 00789703-00789710; 00834849-00834856 | Names of Prisoners from Division 603 | P | 00086766 | 00789707 | 00834853 |
| E3/9524 | D119/100 | 00978928-00978935; 00985171-00985180; 00988961-00988968 | Written Record of Interview for CHEAM Kin 21 | SC | 00978933 | 00985176-00985177 | 00988965 |
| E3/9567 | D119/136 | 01003839-01003851; 01044759-01044775 | Written Record of Interview for PAN Chhuong. | SC | 01003843; 01003846 | 01044764; 01044769 | / |
| E3/9076 | | 00728841-00728896; 00731151-00731190 | Khmer Rouge 'Trapeang Thma' Dam Construction Interview Series: Interview No. 4 – Interview with MUN Mut | P | 00728870-00728871 | 00731172 | / |

<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៨)
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥។(១៦.០៦)

01186617



| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឯម ហ៊ុយ** Matthew McCarthy